**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខ: ៥៤៤៣៥ ប្រក

# ប្រកាស
## ស្តីពី
## ការបង្កើត និងការដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញា
## រដ្ឋបាលស្រុកស្ទោង ខេត្តកំពង់ធំ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនង ការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ១៨៤ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារនិងរចនាសម្ព័ន្ធរដ្ឋបាលស្រុក
- យោងតាមសំណើរបស់រដ្ឋបាលខេត្តកំពង់ធំ

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតនិមិត្តសញ្ញារដ្ឋបាលស្រុកស្ទោង ខេត្តកំពង់ធំ មានរូបរាង រូបភាព និងលក្ខណៈសម្គាល់ដូចខាងក្រោម៖

- និមិត្តសញ្ញាមានរាងមូលព័ទ្ធដោយខ្សែវណ្ឌមួយជាន់ពណ៌ខៀវ បង្ហាញអំពីការគ្រប់គ្រងដែនដីរបស់រដ្ឋបាលស្រុក
- ធ្នូពណ៌មាសដាក់ព្រួញជាប់នឹងសសរប្រាំបីជ្រុង ដែលមានទម្រខឿនបីជាន់ពណ៌មាស ជាតំណាងនៃអាវុធមួយប្រភេទសម្រាប់បាញ់ព្រួញរបស់ស្តេចព្រះនាមថាព្រះបាទសិន្ធ្រា ដែលបានគង់នៅស្រុកស្ទោង នៅក្នុងរឿងព្រេងខ្មែរបក្សីចាំក្រុង។ ធ្នូនេះរចនាក្បាច់ចុងសងខាងជាសត្វនាគ ជាអាវុធទិព្វមានមហិទ្ធិឫទ្ធិពូកែអស្ចារ្យណាស់ បាញ់ម្តងបានប្រាំព្រួញសូរសំឡេងប្រៀបដូចរន្ទះបាញ់ ហើយធ្នូនេះមិនអាចដាក់ផ្ទាល់នឹងដីនិងលើគ្រែបានឡើយ ទើបព្រះបាទសិន្ធ្រាសង់ប្រាសាទធ្វើពីឥដ្ឋសម្រាប់ទុកព្រួញធ្នូនិងសសរប្រៀបដូចនឹងទោង ហើយអ្នកភូមិនិយមហៅថាសរទោង ឬពាក្យស្ទោងរហូតដល់សព្វថ្ងៃនេះ
- សសរប្រាំបីជ្រុងមានកំពូលរចនាជាកំពូលប្រាសាទបក្សីចាំក្រុងពណ៌មាស សសរនេះទ្រដោយខឿនបីថ្នាក់ ដែលថ្នាក់ផ្ទាល់ដីឬខាងក្រោមមានសត្វតោពណ៌មាសចំនួន៤ក្បាល ថ្នាក់កណ្តាលបង្កោលសីមាពណ៌មាស និងថ្នាក់ខាងលើមានប្រាំជ្រុង បង្ហាញអំពីភាពរឹងមាំក្នុងការតម្កល់រក្សាទុកធ្នូ
- អក្សរឈ្មោះ «រដ្ឋបាលស្រុកស្ទោង» មានពណ៌ស រំលេចក្នុងខ្សែបូពណ៌ក្រហម អមដោយខ្សែពណ៌ខៀវ
- ផ្ទៃពណ៌ស បង្ហាញអំពីភាពជឿជាក់ ភាពស្មោះត្រង់ និងភាពត្រជាក់ត្រជុំ។

**ប្រការ២ .-**

ត្រូវបានដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញារដ្ឋបាលស្រុកស្ទោង ខេត្តកំពង់ធំ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

និមិត្តសញ្ញារដ្ឋបាលស្រុកស្ទោង ខេត្តកំពង់ធំ ត្រូវប្រើប្រាស់ដូចខាងក្រោម៖

- ដាក់នៅកន្លែងធ្វើការងារនៅរដ្ឋបាលស្រុកស្ទោង
- ប្រើប្រាស់នៅលើលិខិត ស្រោមសំបុត្រ និងឯកសារផ្លូវការពាក់ព័ន្ធរបស់រដ្ឋបាលស្រុកស្ទោង
- ប្រើប្រាស់ក្នុងពិធីនានា និងប្រើប្រាស់ក្នុងកិច្ចការជាផ្លូវការផ្សេងៗ តាមការចាំបាច់។

**ប្រការ៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤ .-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានមនុស្ស ប្រធានអង្គភាពផ្សេងទៀតចំណុះក្រសួងមហាផ្ទៃ ប្រធានក្រុមប្រឹក្សានិងអភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ ប្រធានក្រុមប្រឹក្សានិងអភិបាលនៃគណៈអភិបាលស្រុកស្ទោង ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ..សុក្រ....១១កើត.... ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..១៣..ខែ..កញ្ញា.....ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- លេខាធិការដ្ឋាន គ.ជ.អ.ប.
- រដ្ឋបាលខេត្តកំពង់ធំ
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ៥៤២៥ប្រក ចុះថ្ងៃ.ពុធ..១១កើត..ខែកត្តិក....ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹង
ថ្ងៃទី១៣.ខែវិច្ឆិកា.ឆ្នាំ២០២៤ ស្តីពីការបង្កើត និងការដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញារដ្ឋបាលស្រុកស្ទោង ខេត្តកំពង់ធំ។

**និមិត្តសញ្ញារដ្ឋបាលស្រុកស្ទោង** ១/៥